ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងព្រហ្មទណ្ឌ
លេខ ០០៩ អ.ក
ចុះថ្ងៃទី០២.មករា.២០២៤
សាលក្រមលេខ: ៦៨ /ច
ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០២៤

## តាមនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តកណ្តាល បានបើកសវនាការជាសាធារណៈ នាថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៤ ដោយមានសមាសភាពដូចតទៅ៖

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ជាចៅក្រមប្រឹក្សា
លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្តាល

**មេធាវី**

លោក [redacted] ជាមេធាវីការសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] តុលា។

## ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ ០០៩ អ.ក ចុះថ្ងៃទី០២.មករា.២០២៤ ដែលមានជនជាប់ចោទ:

ឈ្មោះ [redacted] តុលា ភេទប្រុស អាយុ ១៦ ឆ្នាំ ជនជាតិខ្មែរ មុខរបរ លក់ដូរ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិក [redacted] ខេត្តតាកែវ ឪពុកឈ្មោះ មិនស្គាល់ ម្តាយឈ្មោះ [redacted] តា (រស់) នៅលើវ ជាអនីតិជន ទោសពីមុខគ្មាន។ (ក្នុងឃុំ)

ជាប់ចោទពីបទ: បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យរបួសអ្នកដទៃ (គ្មានប័ណ្ណបើកបរ) ប្រព្រឹត្តចំណុចផ្លូវជាតិលេខ: ៥១ ចន្លោះគីឡូម៉ែត្រលេខ ២៩-៣០ ស្ថិតនៅភូមិតីរីថ្មី ឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌ តាមមាត្រា ៨៣ ចំណុច ក នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

-ដើមបណ្តឹងរដ្ឋប្បវេណី ឬជនរងគ្រោះឈ្មោះ [redacted] ស្រីកា (ត្រូវជាកូនរបស់ជនរងគ្រោះ) អាយុ២៤ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិតីរីថ្មី ឃុំសំរោងលើ ស្រុកអង្គ ស្នួល ខេត្តកណ្តាល។



Scanned with CamScanner

*អង្គហេតុនៃរឿងមានដូចតទៅ៖*

នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤ វេលាម៉ោង ១៦ និង ៣៥ នាទី មានករណីគ្រោះថ្នាក់ចរាចរណ៍ មួយកើតឡើងចំណុចផ្លូវលេខ៥១ ចន្លោះគីឡូម៉ែត្រលេខ ២៩-៣០ ស្ថិតនៅក្នុងភូមិគិរីថ្មី ឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្ដាល ដោយមានម៉ូតូមួយគ្រឿងម៉ាកហុងដាឌ្រីម C125 ពណ៌ខ្មៅ ពាក់ ស្លាកលេខ ភ្នំពេញ 1CI-4054 បើកបរដោយឈ្មោះ [redacted] ជា ភេទស្រី អាយុ ៤៨ឆ្នាំ ដោយមានអ្នក រួមដំណើរម្នាក់ឈ្មោះ [redacted] នីតា ភេទស្រី អាយុ ០៣ ឆ្នាំ ក្នុងទិសដៅពីជើងទៅត្បូង។ ពេលបើកបរមកដល់ចំណុចកើតហេតុម៉ូតូក៏បានបត់ឆ្វេង ហើយក៏ត្រូវម៉ូតូមួយគ្រឿងម៉ាក YAMAHA Exciter C150 ពណ៌លឿង គ្មានផ្លាកលេខ បើកបរដោយឈ្មោះ [redacted] គុលា ភេទប្រុស អាយុ ១៦ ឆ្នាំ គ្មានប័ណ្ណបើកបរ បុកបណ្ដាលឱ្យអ្នកបើកបរម៉ូតូហុកឌ្រីម C125 ឈ្មោះ [redacted] ជា រងរបួសធ្ងន់, អ្នករួមដំណើរឈ្មោះ [redacted] នីតា រងរបួសស្រាល ចំណែកអ្នកបើកបរម៉ូតូម៉ាក YAMAHA Exciter C150 រងរបួសស្រាលដែរ។ ក្រោយកើតហេតុសមត្ថកិច្ចបានវាស់វែង និងបានធ្វើការឃាត់ខ្លួន អ្នកបើកបរម៉ូតូម៉ាក YAMAHA Exciter C150 រួចក៏បានកសាងសំណុំរឿងបញ្ជូន មកអយ្យការអមសាលាដំបូងខេត្តកណ្ដាល ដើម្បីចាត់ការតាមនីតិវិធី តែម្ដង។

បានឃើញ ដីកាដំណោះស្រាយលេខ ២៥១ ដកដស ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ ២០២៤ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្ដាល។

បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ៣២៣ ដកចត ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៤ របស់ប្រធានសាលាដំបូងខេត្តកណ្ដាល។

## នាពេលសវនាការ

-ចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted] គុលា ឆ្លើយថា: នៅថ្ងៃទី០១ ខែ មករា ឆ្នាំ២០២៤ ខ្លួនបានជិះម៉ូតូម៉ាក YAMAHA Exciter C150 ពណ៌លឿង គ្មានផ្លាក លេខ ក្នុងទិសដៅពីឧត្តុង ទៅថ្នល់ទទឹង ក្នុងល្បឿន ៤០ គីឡូម៉ែត្រ ក្នុងមួយម៉ោង។ ពេលបើកបរមកដល់ចំណុចផ្លូវលេខ៥១ ចន្លោះគីឡូម៉ែត្រលេខ ២៩-៣០ ស្ថិតនៅក្នុងភូមិគិរីថ្មី ឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្ដាល ក៏មាន ម៉ូតូមួយគ្រឿងម៉ាកហុងដាឌ្រីម C125 ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 1CI-4045 ជិះដោយមនុស្សស្រីម្នាក់ និងដៃម្ខាងបីក្មេងស្រីម្នាក់ បើកបរបត់ឆ្វេង គ្មានបើកភ្លើងស៊ីញ៉ូទេ ហើយក៏ត្រូវម៉ូតូរបស់ខ្លួនបុកតែម្ដង។ នៅពេលដែលខ្លួនបើកបរមិនបានផឹកគ្រឿងស្រវឹងទេ ខ្លួនបើកបរ គឺគ្មានប័ណ្ណបើកបរនោះទេ។

-អានរបាការណ៍សរុបលេខ: ០៤/២៤ រ.ប.ក របស់អធិការដ្ឋាននគរបាលស្រុកអង្គស្នួល ខេត្តកណ្ដាល បានធ្វើសេចក្ដីសន្និដ្ឋានថា: អ្នកបើកបរម៉ូតូហុងដាឌ្រីម C125 បើកបរមានការធ្វេសប្រហែលមិនបានមើលស្ថានភាពផ្លូវអោយបានគ្រប់ជ្រុងជ្រោយ មុននឹងបត់ឆ្វេងឆ្លងផ្លូវ និងអ្នកបើកបរម៉ូតូម៉ាក YAMAHA Exciter C125 បើកបរក្នុងល្បឿងលឿនខ្វះការប្រុងប្រយ័ត្ន និងគ្មានប័ណ្ណបើកបរ។

-អានកំណត់ហេតុស្ដីពីការប្រគល់ និងទទួល ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០២៤ ដែលមានខ្លឹមសារថា: ឈ្មោះ [redacted] ចាន់នាង ភេទប្រុស អាយុ៣៨ឆ្នាំ មានទីលំនៅបច្ចុប្បន្ន



Scanned with CamScanner

នៅភូមិស្រងៃ ឃុំជើងរាស ស្រុក សាមគ្គីមានជ័យ ខេត្តកំពង់ស្ពឺ ត្រូវជាអ៊ុំរបស់ជនត្រូវចោទ ឈ្មោះ [redacted] តុលា ភេទប្រុស អាយុ១៦ឆ្នាំ បានប្រគល់ប្រាក់ចំនួន ៦០០ (ប្រាំមួយរយ) ដុល្លារអាមេរិក ទៅឱ្យឈ្មោះ [redacted] ស្រីកា ភេទស្រី អាយុ២៨ឆ្នាំ (ដែលត្រូវជាកូនរបស់ជនរងគ្រោះឈ្មោះ [redacted] ដា)។

-តំណាងអយ្យការសន្និដ្ឋាន: ពិតជាមានពិរុទ្ធ និង ភស្តុតាង ដាក់បន្ទុកលើជនជាប់ចោទ ឈ្មោះ [redacted] តុលា ភេទប្រុស អាយុ ១៦ ឆ្នាំ ពីបទ បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យរបួសអ្នកដទៃ (គ្មានប័ណ្ណបើកបរ) ប្រព្រឹត្តចំណុចផ្លូវជាតិលេខ: ៥១ ចន្លោះគីឡូម៉ែត្រលេខ ២៩-៣០ ស្ថិតនៅភូមិគីរីថ្មី ឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌ តាមមាត្រា ៨៣ ចំណុច ក នៃច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោក។

-មេធាវីជនត្រូវចោទធ្វើសេចក្តីសន្និដ្ឋាន: តាមរបាការណ៍សរុបលេខ: ០៤/២៤ រ.ប.ក របស់អធិការដ្ឋាននគរបាលស្រុកអង្គស្នួល ខេត្តកណ្តាល បានធ្វើសេចក្តីសន្និដ្ឋានថា: អ្នកបើកបរម៉ូតូហុងដាឌ្រីម C125 ឈ្មោះ [redacted] ដា (ជនរងគ្រោះ) បើកបរមានការធ្វេសប្រហែលមិនបាន មើលស្ថានភាព ផ្លូវអោយបានគ្រប់ជ្រុងជ្រោយ មុននឹងបត់ឆ្វេងឆ្លង ផ្លូវ ស្នើសុំឱ្យតុលាការមេត្តា បន្ធូបន្ថយទោស ឱ្យកូនក្តីរបស់ខ្លួនផង ព្រោះកូនក្តីរបស់ខ្លួនដឹងកំហុសខុសឆ្គងហើយ ណាមួយកូនក្តី របស់ខ្លួនជាអនីតិជន ទៀតផង។

ក្រោយពីបានស្តាប់ចម្លើយជនត្រូវចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

ក្រោយពីបានថយទៅពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា:

ក.ពិរុទ្ធភាព:

១-ដីកាដំណោះស្រាយលេខ ២៥១ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៤ បានសម្រេចបញ្ជូនជនត្រូវចោទឈ្មោះ [redacted] តុលា ពីបទ: បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យរបួសអ្នកដទៃ (គ្មានប័ណ្ណបើកបរ) ប្រព្រឹត្តចំណុចផ្លូវជាតិលេខ: ៥១ ចន្លោះគីឡូម៉ែត្រលេខ ២៩-៣០ ស្ថិតនៅភូមិគីរីថ្មី ឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌ តាមមាត្រា ៨៣ ចំណុច ក នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ទៅជំនុំជម្រះ។

២-តាមចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted] តុលា ឆ្លើយថា: នៅថ្ងៃទី០១ ខែ មករា ឆ្នាំ២០២៤ ខ្លួនបានជិះម៉ូតូម៉ាក YAMAHA Exciter C150 ពណ៌លឿង គ្មានផ្លាក លេខ ក្នុងទិសដៅពីឧត្តុង ទៅថ្នល់ទទឹង ក្នុងល្បឿន ៨០ គីឡូម៉ែត្រ ក្នុងមួយម៉ោង។ ពេលបើកបរមកដល់ចំណុចផ្លូវលេខ៥១ ចន្លោះគីឡូម៉ែត្រលេខ ២៩-៣០ ស្ថិតនៅក្នុងភូមិគិរីថ្មី ឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្តាល ក៏មាន ម៉ូតូមួយគ្រឿងម៉ាកហុងដាឌ្រីម C125 ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 1CI-4045 ជិះដោយមនុស្សស្រីម្នាក់ និងដៃម្ខាងបីក្មេងស្រីម្នាក់ បើកបរបត់ឆ្វេង គ្មានបើកភ្លើងស៊ីញ៉ូទេ ហើយក៏ត្រូវម៉ូតូរបស់



Scanned with CamScanner

ខ្លួនបុកតែម្តង។ នៅពេលដែលខ្លួនបើកបរមិនបានផឹកគ្រឿងស្រវឹងទេ ខ្លួនបើកបរ គឺគ្មានប័ណ្ណបើកបរនោះទេ។

៣-តាមរបាការណ៍សរុបលេខ: ០៤/២៤ រ.ប.ក របស់អធិការដ្ឋាននគរបាលស្រុកអង្គស្នួល ខេត្តកណ្តាល បានធ្វើសេចក្តីសន្និដ្ឋានថា: អ្នកបើកបរម៉ូតូហុងដាឌ្រីម C125 បើកបរមានការ ធ្វើប្រហែលមិនបានមើលស្ថានភាពផ្លូវអោយបានគ្រប់ជ្រុងជ្រោយ មុននឹងបត់ឆ្វេងឆ្លងផ្លូវ និងអ្នកបើកបរម៉ូតូម៉ាក YAMAHA Exciter C125 បើកបរក្នុងល្បឿនលឿនខ្វះការ ប្រុងប្រយ័ត្ន និងគ្មានប័ណ្ណបើកបរ។

៤-ផ្អែកតាមអង្គហេតុដែលកើតមាន ,ចម្លើយរបស់ជនត្រូវចោទ ,តាមរបាយការណ៍សរុបរបស់អធិការនគរបាលស្រុកអង្គស្នួល និងវត្ថុតាងគឺ មានភាពស៊ីចង្វាក់គ្នាដែលអាចបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] តុលា ពិតជាបាន បើកបរដោយធ្វេសប្រហែសខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យរបួសអ្នកដទៃ (គ្មានប័ណ្ណបើកបរ) ប្រព្រឹត្តចំណុចផ្លូវជាតិលេខ: ៥១ ចន្លោះគីឡូម៉ែត្រលេខ ២៩-៣០ ស្ថិតនៅភូមិគីរីថ្មី ឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌ តាមមាត្រា ៨៣ ចំណុច ក នៃច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោក។

៥-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] តុលា មានជាតុផ្សំគ្រប់គ្រាន់ ជាបទល្មើស បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យរបួសអ្នកដទៃ (គ្មានប័ណ្ណបើកបរ) ប្រព្រឹត្តចំណុចផ្លូវជាតិ លេខ: ៥១ ចន្លោះគីឡូម៉ែត្រលេខ ២៩-៣០ ស្ថិតនៅភូមិគីរីថ្មី ឃុំសំរោងលើ ស្រុកអង្គស្នួល ខេ
ត្តកណ្តាល កាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌ តាមមាត្រា ៨៣ ចំណុច ក នៃច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោក។

៦-ជនជាប់ចោទឈ្មោះ [redacted] តុលា មានស្មារតីធម្មតាអាចយល់ដឹងពីបច្ច័យ និងព្យសនកម្មដែលកើតឡើងពីអំពើរបស់ខ្លួន ដែលបានប្រព្រឹត្តបានប្រព្រឹត្ត។ ដូចនេះត្រូវតែទទួលខុសត្រូវចំពោះមុខច្បាប់។

៧-មានភស្តុតាង បញ្ជាក់ពីពិរុទ្ធលើជនជាប់ចោទឈ្មោះ [redacted] តុលា ពីបទ: បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យរបួសអ្នកដទៃ (គ្មានប័ណ្ណបើកបរ) ប្រព្រឹត្តចំណុចផ្លូវជាតិលេខ: ៥១ ចន្លោះគីឡូម៉ែត្រលេខ ២៩-៣០ ស្ថិតនៅ ភូមិគីរីថ្មី ឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌ តាមមាត្រា ៨៣ ចំណុច ក នៃច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោក។

ខ.អំពីវត្ថុតាងរួមមាន: ម៉ូតូមួយគ្រឿងម៉ាក YAMAHA Cxciter C125 ពណ៌លឿងគ្មានផ្លាកលេខ។

គ.អំពីសំណង: ដើមបណ្តឹងរដ្ឋប្បវេណីឬជនរងគ្រោះឈ្មោះ [redacted] ស្រីកា (ត្រូវជាកូនរបស់ជនរងគ្រោះ) អាយុ២៤ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិគីរីថ្មី ឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្តាល បានទទួលសំណង រួចរាល់ហើយ ដូច្នេះមិនអាចឱ្យតុលាការសម្រេច និងពិចារណាសម្រេចអំពីសំណងទៀតនោះទេ។



Scanned with CamScanner

ឃ.អំពីទោសៈ

**ហេតុដូច្នេះ-តុលាការ**

**<u>សម្រេច</u>**

១.ផ្តន្ទាទោសលើ

-ជនជាប់ចោទឈ្មោះ [redacted] តុលា (មានសាវតាជាតិគ្រប់គ្រាន់ដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០៦ (ប្រាំមួយ) ខែ។

ពីបទ បើកបរ ដោយធ្វេសប្រហែស ខ្វះខ្វា មិនប្រុងប្រយ័ត្នបណ្តាលឱ្យរបួសអ្នកដទៃ (គ្មានប័ណ្ណបើកបរ) ប្រព្រឹត្តចំណុចផ្លូវជាតិលេខៈ ៥១ ចន្លោះគីឡូម៉ែត្រលេខ ២៩-៣០ ស្ថិតនៅ ភូមិគីរីថ្មី ឃុំ សំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤ បទល្មើស ព្រហ្មទណ្ឌ តាមមាត្រា ៨៣ ចំណុច ក នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

២.វត្ថុតាងរួមមាន ម៉ូតូមួយគ្រឿងម៉ាក YAMAHA Cxciter C125 ពណ៌លឿង គ្មានផ្លាកលេខ ប្រគល់មកឱ្យម្ចាស់ដើមវិញ។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤ ,កំបាំងមុខដើមរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីកា និងចំពោះមុខជនត្រូវចោទឈ្មោះ [redacted] តុលា និងទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ ចៅក្រមប្រឹក្សា ចៅក្រមប្រឹក្សា ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

---

បានចម្លងត្រឹមត្រូវតាមសាលក្រមដើម

*ថ្ងៃ ពុធ ១ កើត ខែ ពិសាខ ឆ្នាំ រោង ឆស័ក ព.ស ២៥៦៧*

កណ្តាល,ថ្ងៃទី០៨ ខែ ឧសភា ឆ្នាំ ២០២៤

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

Scanned with CamScanner